MEDIARELEASE

| |
|---|
| ថ្ងៃសុក្រ ទី៧ ខែតុលា ឆ្នាំ២០១៦ |
| **ទំនាក់ទំនង ៖** Fontella Koleff A/ នាយកផ្នែកគមនាគមន៍ ក្រសួងឧស្សាហកម្មវត្ថុធាតុដើម 8429 0488/0423 296 579 |
| តាមយើងនៅ Twitter @SA_PIRSA |

PRIMARY INDUSTRIES & REGIONS SA
**PIRSA**

**ដំណាក់កាលងើបឡើងវិញចាប់ផ្តើមហើយ សម្រាប់អ្នកផលិតសាកវប្បកម្មដែលរងប៉ះពាល់ ដោយទឹកជំនន់**

ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងងើបឡើងវិញពីទឹកទឹកជំនន់របស់រដ្ឋាភិបាលប្រចាំរដ្ឋ ក្រុមវាយតម្លៃមកពីក្រសួងឧស្សាហកម្មវត្ថុធាតុដើម និងតំបន់ភូមិភាគ SA (PIRSA) បានចាប់ផ្តើមប្រតិបត្តិការនៅក្នុងតំបន់ដែលរងប៉ះពាល់ដោយទឹកជំនន់នៃ Northern Adelaide Plains (ដីទំនាបនៅតំបន់ភាគខាងជើងក្រុងអាដឺឡែត)។

បច្ចុប្បន្ននេះ ក្រុមនេះកំពុងជួបជាមួយអ្នកផលិតដើម្បីវាយតម្លៃការខូចខាតកើតមានដល់ដំណាំលក់តាមទីផ្សារ ផលដំណាំ បសុសត្វ អាគារកសិកម្ម និងឧបករណ៍ទាំងឡាយ។

ប្រតិបត្តិការងើបឡើងវិញក៏នឹងវាយតម្លៃផងដែរ លើបញ្ហានៃលទ្ធភាពទទួលបានទឹកស្អាត កាកសំណល់សរីរាង្គ និងការចោលកាកសំណល់។

ក្នុងការសហការជាមួយសាលាក្រុង និងក្រុមឧស្សាហកម្ម PIRSA នឹងសម្របសម្រួល ហើយគាំទ្រដល់កម្មវិធីនៃការយកទឹកចេញពីដីធ្លីកសិកម្មដែលបានរងប៉ះពាល់។

PIRSA កំពុងលើកទឹកចិត្តដល់អ្នកផលិតសាកវប្បកម្ម ដើម្បីនិយាយទៅកាន់ពួកគេអំពីការខូចខាតដោយទឹកជំនន់កើតមានដល់អាជីវកម្មរបស់ពួកគេ ទាំងតាមរយៈក្រុមការវាយតម្លៃនៅតាមទីវាល ឬខ្សែទូរស័ព្ទទាន់ហេតុការណ៍២៤ម៉ោង - **(08) 8207 7847**។

ព័ត៌មានបន្ថែមអាចទទួលយកបាននៅត្រង់វិបសាយ www.pirsa.gov.au/emergency_management

**សម្រង់ចេញពីស្តីទីនាយកប្រតិបត្តិរង Will Zacharin**

PIRSA កំពុងធ្វើទំនាក់ទំនងជាមួយភ្នាក់ងាររដ្ឋាភិបាលដទៃទៀត ដើម្បីធានាបាននូវវិធីសាស្រ្តការសម្របសម្រួលទាំងអស់របស់រដ្ឋាភិបាលដើម្បីខិតខំប្រឹងប្រែងងើបឡើងវិញពីទឹកជំនន់។

នៅពេលទំហំពេញលេញនៃការខូចខាតដោយទឹកជំនន់ត្រូវបានវាយតម្លៃ យើងនឹងកំណត់នូវអ្វីដែលយើងអាចផ្តល់ជូនជំនួយ។

ដើម្បីជួយឱ្យទទួលបានការវាយតម្លៃត្រឹមត្រូវ ហេតុនេះហើយបានជាយើងសូមលើកទឹកចិត្តអ្នកដាំដុះ និងអ្នកផលិតដែលបានរងប៉ះពាល់ដោយទឹកជំនន់ទាំងនេះ ទាក់ទងជាមួយ PIRSA ស្តីពីការខាតបង់ និងបញ្ហានានាដែលពួកគេកំពុងប្រឈមនាពេលបច្ចុប្បន្ន ដើម្បីឱ្យយើងអាចចាប់ផ្តើមជួយពួកគេងើបឡើងវិញ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

**ផ្ទៃរឿង**

តំបន់ដែលរងប៉ះពាល់ខ្លាំងបំផុតដោយទឹកជំនន់នៅ Northern Adelaide Plains គឺគ្របដណ្តប់ជាង១១០០ ហិកតា។

នេះត្រូវបានប្រមាណថារវាងអ្នកដាំដុះចំនួន៣០០នាក់ដែលត្រូវបានរងប៉ះពាល់ដោយទឹកជំនន់ខែតុលា រួមចំណែកប្រហែលមួយភាគបីនៃឧស្សាហកម្មដំណាំក្នុងអាគារកញ្ចក់របស់រដ្ឋ។

ដំណាំដែលរងប៉ះពាល់ជាងគេគឺដំឡូង ការ៉ុត ស្ពៃក្តោប ផ្កាខាត់ណា ផ្កាស្ពៃ ត្រសក់ ម្ទេសប្លោក និងប៉េងប៉ោះដាំក្នុងផ្ទះកញ្ចក់។

ពុំមានគ្រោះទឹកជំនន់បន្ថែមទៀតត្រូវបានរំពឹងទុកថា កើតមានពីការហូរទឹកចេញពីស្ទឹង Gawler ឡើយ ។

PREMIUM FOOD AND WINE FROM OUR CLEAN ENVIRONMENT

SOUTH AUSTRALIA

Government of South Australia
Primary Industries and Regions SA